# សេចក្ដីថ្លែងការណ៍នៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយតំណាងពិសេសរបស់លោក អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧

ខ្ញុំបានធ្វើទស្សនកិច្ចរបស់ខ្ញុំជាផ្លូវការមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៧។ គោលដៅចំបងនៃដំណើរទស្សនកិច្ចនេះ គឺដើម្បីពិភាក្សាអំពីរបាយការណ៍ និងអនុសាសន៍របស់ខ្ញុំជាមួយរដ្ឋាភិបាល មុននឹងដាក់បង្ហាញរបាយការណ៍ និងអនុសាសន៍ទាំងនោះជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ខ្ញុំក៏មានបំណងស្វែងយល់បន្ថែមទៀត អំពីស្ថានការណ៍សិទ្ធិមនុស្សថ្មីៗទៀត។ ខ្ញុំបានពិភាក្សាប្រកបដោយផ្លែផ្កា ជាមួយតំណាងសង្គមស៊ីវិល គណបក្សនយោបាយ គណៈកម្មការជាតិរៀបចំការបោះឆ្នោត សហជីពកម្មករ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងសហគមន៍អ្នកការទូតនានា។ នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំមានឱកាសបានជួបប្រជុំជាមួយឯកឧត្តម **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាឧបនាយករដ្ឋមន្ត្រី គឺជាមន្ត្រីរដ្ឋាភិបាលតែម្នាក់គត់ដែលបានទទួលយកការស្នើសុំជួបប្រជុំនេះ ហើយដែលខ្ញុំសូមថ្លែងអំណរគុណ។ ខ្ញុំសូមស្វាគមន៍ការផ្ដល់មតិរបស់រដ្ឋាភិបាល ដែលបានផ្សព្វផ្សាយដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលបានបញ្ជូនមកខ្ញុំកាលពីសប្ដាហ៍មុននេះ។ ទោះបីជាសេចក្ដីផ្ដល់មតិនេះ មិនបានឆ្លើយតបចំពោះបញ្ហាស្នូលដែលខ្ញុំបានលើកឡើងក្នុងរបាយការណ៍ និងអនុសាសន៍របស់ខ្ញុំក៏ដោយ ក៏ខ្ញុំជឿជាក់ថា សេចក្ដីផ្ដល់មតិទាំងនេះ ផ្ដល់នូវមូលដ្ឋានមួយសំរាប់ការពិគ្រោះយោបល់ និងការពិភាក្សាបន្ថែមទៀត ជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិល។

ខ្ញុំបានបញ្ចប់របាយការណ៍នេះនៅចុងឆ្នាំ២០០៦ ជាឆ្នាំដែលបានរំលឹកដល់ខួបលើកទី១៥នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលបានបញ្ចប់សង្គ្រាម និងជំលោះស៊ីវិល។ ចាប់ពីពេលនោះមក កម្ពុជាមានការរីកចំរើនគួរអោយកត់សំគាល់ ដោយមានការជួយឧបត្ថម្ភពីអន្តរជាតិយ៉ាងច្រើន ក្នុងការកសាងកម្ពុជាឡើងវិញ។ ប្រទេសនេះបានស្ថិតក្រោមរដ្ឋបាលឯកភាពមួយ។ ចាប់ពីថ្នាក់មូលដ្ឋាន មានការរីកចំរើនក្នុងវិស័យអប់រំ និងសុខាភិបាល។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ អត្រាកំណើនសេដ្ឋកិច្ច មានការកើនឡើងគួរឱ្យចាប់អារម្មណ៍។

ការបោះឆ្នោតត្រូវបានរៀបចំឡើង ដោយកំរិតនៃភាពត្រឹមត្រូវ មានការប្រែប្រួល។ ការបោះឆ្នោតនៅពេលថ្មីៗនេះ គឺជាការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយសន្តិវិធីដែលគួរអោយកត់សំគាល់។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការបោះឆ្នោត នៅតែមិនទាន់មានភាពឯករាជ្យពេញលេញ ពីការត្រួតត្រារបស់រដ្ឋាភិបាល ហើយត្រូវចាត់វិធានការតទៅទៀត ដើម្បីធានាថា ការចុះបញ្ជីអ្នកបោះឆ្នោត និងការបោះឆ្នោត មិនត្រូវផ្ដេកផ្ដួលលើការប្រើឧបាយកលបញ្ឆោតនៅថ្នាក់មូលដ្ឋានឡើយ។ ការបោះឆ្នោតជាតិ នឹងត្រូវធ្វើនៅឆ្នាំក្រោយ ហើយមានអត្ថប្រយោជន៍យ៉ាងច្រើន ក្នុងការពិនិត្យឡើងវិញអំពីប្រព័ន្ធបោះឆ្នោត ដើម្បីធានាឱ្យការបោះឆ្នោតនោះមានភាពឯករាជ្យ។ ប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោត ដែលខ្ញុំបានជួបប្រជុំប្រកបដោយផ្លែផ្កា បានប្រាប់ខ្ញុំអំពី

ចេតនារបស់គណៈកម្មការ ដើម្បីពិនិត្យ និងលុបបំបាត់ចំណុចខ្សោយមួយចំនួន ដែលបានកើតឡើងនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ។

នេះក៏ជាកំណត់សំគាល់វិជ្ជមានមួយដែរ កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម កាលពីខែមករា ឆ្នាំ២០០៧ ។ នេះគឺជាការវិវត្តន៍មួយគួរឱ្យស្វាគមន៍ ហើយជាឱកាសដ៏ល្អមួយសំរាប់រដ្ឋាភិបាល ពិនិត្យរបាយការណ៍របស់ខ្លួន តាមអនុសញ្ញានេះ និងបន្តការប្រឹងប្រែងថ្មីៗទៀត ដើម្បីអនុវត្តអនុសាសន៍ទាំងអស់របស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម ។ ឥឡូវនេះ យន្តការជាតិឯករាជ្យមួយ ត្រូវតែបង្កើតឡើង ក្នុងរយៈពេលមួយឆ្នាំ ស្របតាមគោលការណ៍ទីក្រុងប៉ារីស ដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

ខ្ញុំដឹងថា ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័ត នៅទីបំផុត ។ ខ្ញុំសូមស្វាគមន៍ចំពោះការអនុម័តនេះ ហើយសង្ឃឹមថា ក្រមនេះនឹងត្រូវបានដាក់ឱ្យអនុវត្តយ៉ាងឆាប់រហ័ស ។ ខ្ញុំក៏សង្ឃឹមដែរថា ច្បាប់ដទៃទៀត ដែលគេទន្ទឹងរង់ចាំជាយូរមកហើយនោះ ក៏នឹងត្រូវបានអនុម័តនៅពេលដ៏ឆាប់ខាងមុខនេះដែរ ។

ខ្ញុំសូមស្វាគមន៍ចំពោះការវិវត្តន៍ជាវិជ្ជមានទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ វិស័យភាគច្រើនដែលគ្របដណ្តប់នៅក្នុងអាណត្តិរបស់ខ្ញុំ មានការរីកចំរើនតិចតួចបំផុត ។ កង្វល់ដ៏សំខាន់មួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស គឺការបង្កើតអោយបានពេញលេញនូវតំលៃ និងការអនុវត្តន៍លិទ្ធិប្រជាធិបតេយ្យ និងសារសំខាន់ជាចំបងនៃការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស ក្នុងការស្តារ និងការរក្សាសន្តិភាព និងភាពរុងរឿង សំរាប់ប្រជាជនកម្ពុជាទាំងអស់ ។ នៅក្នុងកិច្ចព្រមព្រៀងទាំងនេះ អាជ្ញាធរកម្ពុជាមានភារកិច្ចការពារសិទ្ធិមនុស្ស ហើយធានាថាគោលនយោបាយ និងការអនុវត្តន៍ពីអតីតកាល មិនអាចវិលត្រឡប់វិញឡើយ ។ កិច្ចប្រមព្រៀងទាំងនេះ បានចែងលំអិតអំពីបទបញ្ញត្តិសិទ្ធិមនុស្ស ដែលត្រូវដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញថ្មី ហើយតម្រូវឱ្យមានការអនុវត្តន៍សិទ្ធិមនុស្ស ដោយតុលាការមួយឯករាជ្យ និងថា "ជនរងគ្រោះ" អាចអនុវត្តសិទ្ធិរបស់ខ្លួននៅចំពោះមុខតុលាការបាន ។ ការប្រកាន់ខ្ជាប់នូវលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ក៏ជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងទាំងនេះដែរ ។ កិច្ចព្រមព្រៀងទាំងនេះក៏មាន បទបញ្ញត្តអោយបង្កើតការិយាល័យសំរាប់អ្នករាយការណ៍ពិសេសខាងសិទ្ធិមនុស្សដែរ ។

*កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ*

នៅក្នុងរបាយការណ៍នេះ និងរបាយការណ៍មុនៗរបស់ខ្ញុំ ខ្ញុំបានស្នើយ៉ាងទទូចឱ្យធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការជាមូលដ្ឋាន ។ ហេតុដែលត្រូវធ្វើបែបនេះព្រោះថាបើគ្មានប្រព័ន្ធមួយត្រឹមត្រូវសំរាប់ការដោះស្រាយការការពារប្រឆាំងនឹងការគាបសង្កត់របស់រដ្ឋ ឬមិនមែនរដ្ឋ និងគ្មានប្រព័ន្ធតុលាការមួយមិនលំអៀងដែលធានាអោយមានការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះមនុស្សគ្រប់រូបទេ នោះប្រាកដជាមានការរំលោភសិទ្ធិមនុស្ស ហើយប្រព័ន្ធច្បាប់នឹងត្រូវគេប្រើប្រាស់សំរាប់បិទបាំងការរំលោភទាំងនោះ ។ ដោយមានការគូសបញ្ជាក់ជាច្រើន ខ្ញុំបាន

វាយការណ៍ថា នេះគឺជាហេតុការណ៍ដែលកើតមានយ៉ាងពិតប្រាកដក្នុងប្រទេសកម្ពុជា។ នៅចំពោះមុខអនុសាសន៍របស់ខ្ញុំ ថាគួរអនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ឯករាជ្យដូចបានធានានៅក្នុងរដ្ឋធម្មនុញ្ញ។ ប្រធានក្រុមប្រឹក្សានេះត្រូវបានជ្រើសតាំងជាសមាជិកមួយរូបនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រជាជនកម្ពុជា កាលពីខែមីនា ឆ្នាំនេះ ទោះបីជាខ្ញុំដឹងថា អាណត្តិរបស់គាត់ក្នុងក្រុមប្រឹក្សានេះ នឹងចប់នៅពេលដ៏ឆាប់ៗនេះក៏ដោយ។

នៅក្នុងរបាយការណ៍របស់ខ្ញុំ ខ្ញុំពិភាក្សាអំពីករណីនៃបុរសពីរនាក់ដែលត្រូវបានចោទប្រកាន់ពីបទឃាតកម្មលើ**លោក ជា វិជ្ជា** ប្រធានសហជីពកម្មករ ក្នុងខែមករា ឆ្នាំ២០០៤។ ពួកគេត្រូវបានតុលាការកាត់ទោស ក្នុងខែសីហា ឆ្នាំ២០០៥ ដោយគ្មានភស្តុតាងរឹងមាំ "ចំលើយសារភាព"របស់បុរសម្នាក់ក្នុងចំណោមបុរសទាំងពីរនាក់នេះដែលអះអាងថាត្រូវគេបង្ខិតបង្ខំយកចំលើយនោះ ត្រូវបានដកយកវិញ ហើយការកាត់សេចក្តីនេះមិនបានបំពេញតាមនិយាមជាមូលដ្ឋាននៃចំណាត់ការដ៏ត្រឹមត្រូវឡើយ។ ពួកគេបានចាញ់ក្តីម្តងទៀតនៅសាលាឧទ្ធរណ៍ ក្នុងខែមេសា ឆ្នាំនេះ ទោះបីជាព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានថា "ការស៊ើបអង្កេតរបស់នគរបាល មានចន្លោះប្រហោងច្រើន"។ តុលាការមិនបានពិនិត្យភស្តុតាងធ្ងន់ធ្ងរដែលអាចឱ្យរួចទោស និងការអះអាងដែលថាជនជាប់ចោទនៅកន្លែងផ្សេងមិននៅកន្លែងកើតហេតុនោះទេ។ គេជឿជាទូទៅថា បុរសទាំងពីរនាក់នេះត្រូវបានគេទំលាក់កំហុសលើដើម្បីបិទបាំងឃាតករពិតប្រាកដ ដែលហាក់មានជាប់ពាក់ព័ន្ធក្នុងរឿងនយោបាយ។

ការចោទប្រកាន់ក្នុងរឿងនយោបាយមួយទៀត គឺការចោទប្រកាន់ **ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ** អតីតនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា ត្រូវបានកាត់ទោស និងផ្តន្ទាទោសដោយកំបាំងមុខ ហើយបានរារាំងព្រះអង្គមិនឱ្យធ្វើយុទ្ធនាការឃោសនាបោះឆ្នោតសំរាប់គណបក្សនយោបាយរបស់ព្រះអង្គ ក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់។

ពាក់ព័ន្ធនឹងអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ខ្ញុំសង្ឃឹមថានឹងមានការអនុម័តយ៉ាងឆាប់រហ័សនូវវិធានផ្ទៃក្នុង ដែលបានចំណាយពេលពេញមួយឆ្នាំចាប់ពីការតែងតាំងចៅក្រមសំរាប់តុលាការនេះមក។ គេសង្ឃឹមថា ការកាត់ទោសអាចដំណើរការទៅមុខ ដោយគ្មានការពន្យាពេលតទៅទៀត។ ខ្ញុំក៏ចង់គូសបញ្ជាក់ពីសារសំខាន់នៃការឃ្លាំមើលដោយឯករាជ្យជាអន្តរជាតិចំពោះការកាត់ទោសនេះ ស្របតាមមាត្រា១២នៃកិច្ចព្រមព្រៀង ព្រមទាំងសិទ្ធិ និងភារកិច្ចពិតប្រាកដរបស់អ្នកឃ្លាំមើលដើម្បីពាំនាំកង្វល់ផ្សេងៗប្រាប់ដល់សាធារណៈជន។

អំពើពុករលួយបន្តធ្វើឱ្យខូចដល់ប្រព័ន្ធតុលាការកម្ពុជា។ ការចោទប្រកាន់ធ្ងន់ធ្ងរជាច្រើន រួមទាំង ការសូកប៉ាន់ និង "ការស៊ីសំណូក" ត្រូវបានលើកឡើងអំពីការដែលចៅក្រមកម្ពុជា និងមន្ត្រីដទៃទៀត ត្រូវបានតែងតាំងឱ្យបំរើការក្នុងអង្គជំនុំជំរះវិសាមញ្ញនេះ។ ជាជាងការស៊ើបអង្កេតចំពោះការចោទប្រកាន់ទាំងនេះ មន្ត្រីរដ្ឋាភិបាលបានគំរាមបដិសេធមិនឱ្យបុគ្គលិកអង្គការគំនិតផ្តួចផ្តើមយុត្តិធម៌សង្គមបើកចំហ ដែលបានជំរុញឱ្យធ្វើការស៊ើបអង្កេត

ដែលអាចទុកចិត្តបានលើការចោទប្រកាន់នេះ ។ ការចោទប្រកាន់នេះ ត្រូវតែធ្វើការស៊ើបអង្កេត និងដោះស្រាយ ជៀសវាងធ្វើអោយខូចខាតធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃចំណាត់ការដ៏ត្រឹមត្រូវនិងធ្វើឱ្យខូចដល់តួនាទីរបស់អង្គជំនុំជំរះវិសាមញ្ញ ដែលធ្វើជាគំរូមួយដល់តុលាការផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ។

*សេរីភាពក្នុងការសំដែងមតិ*

ចាប់តាំងពីច្បាប់បានលុបចោលការដាក់ពន្ធនាគារ ជាទោសសំរាប់បទបរិហារកេរ្តិ៍មក រដ្ឋាភិបាល មាននិន្នាការប្រើប្រាស់បទល្មើស "ការផ្សាយព័ត៌មានមិនពិត "ដែលតាមរយៈនេះ ជនជាប់ចោទអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារបាន ។ ការផ្តន្ទាទោសពីបទ "ផ្សាយព័ត៌មានមិនពិត" អាចធ្វើបានតែចំពោះព័ត៌មានដែលមិនពិត ហើយការបោះពុម្ពផ្សាយបានរំខាន ឬទំនងជារំខានដល់សន្តិសុខសាធារណៈ ។ សមាសធាតុទាំងនេះ មិនមាននៅក្នុងរឿងក្តីថ្មីៗនេះទេ ហើយការចោទប្រកាន់ និងការផ្តន្ទាទោស គឺរំលោភច្បាប់ទាំងស្រុង ដើម្បីគាបសង្កត់មតិរិះគន់ ។

ខ្ញុំសូមលើកយកតែឧទាហរណ៍ពីរប៉ុណ្ណោះមកបញ្ជាក់ ។គ្រូបង្រៀនមួយរូបត្រូវបានផ្តន្ទាទោសពីបទ"ផ្សាយព័ត៌មានមិនពិត " ចំពោះការបោះពុម្ពផ្សាយសៀវភៅមួយ ដែលបានរិះគន់ខ្លាំងៗដល់នាយករដ្ឋមន្ត្រី ។ របាយការណ៍ពេទ្យដែលតុលាការបានចាត់តាំង អាចជាភស្តុតាងមួយសំខាន់ដល់ការដោះលែងជនជាប់ចោទនោះឱ្យមានសេរីភាព ត្រូវបានដកយកពីតុលាការ ។ សៀវភៅតែមួយមុខ ត្រូវបានចាត់ទុកជាភស្តុតាងគ្រប់គ្រាន់ សំរាប់ការផ្តន្ទាទោស ហើយជនជាប់ចោទត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះ កាលពីដើមឆ្នាំនេះ ។

សមាជិកបីរូបនៃសហគមន៍ខ្មែរកម្ពុជាក្រោមត្រូវបានចោទប្រកាន់ពីបទ "ផ្សាយព័ត៌មានមិនពិត " ចំពោះការចែកផ្សាយខិតប័ណ្ណបរិហារកេរ្តិ៍នាយករដ្ឋមន្ត្រី ។ ទោះបីជាមិនមានភស្តុតាងភ្ជាប់ពួកគេទៅនឹងខិតប័ណ្ណនោះក៏ដោយ ក៏កាលពីខែកុម្ភៈ ឆ្នាំនេះ ពួកគេត្រូវបានផ្តន្ទាទោស អោយជាប់ពន្ធនាគារដែរ ។ ក្រោយពីបំរើទោសរួច តាមការរាយការណ៍ថា ពួកគេត្រូវបានបង្ខំឱ្យលាក់ខ្លួន ។

*និទណ្ឌភាព*

ខ្ញុំ និងបុព្វធិការីរបស់ខ្ញុំ បានលើកឡើងអំពីបញ្ហានីទណ្ឌភាពចំពោះមិត្តភ័ក្តនៃរបប ក្នុងរបាយការណ៍ដាក់ជូនក្រុមប្រឹក្សា និងគណៈកម្មការសិទ្ធិមនុស្ស ។ ទោះជាយ៉ាងណា រហូតមកទល់ពេលនេះ មានភស្តុតាងតិចតួចណាស់ថា ការអនុវត្តន៍នីទណ្ឌភាពបានរីកចំរើន ឬថាមានការខិតខំប្រឹងប្រែងដែលអាចជឿទុកចិត្តបាន ដើម្បីបញ្ចប់នីទណ្ឌភាព ។ សាលក្រមសាលាឧទ្ធរណ៍ក្នុងករណី **ឈោត ជា ទិដ្ឋា** គឺជាការខកចិត្តបំផុតក្នុងបញ្ហានេះ ។

របាយការណ៍របស់ខ្ញុំនេះ បង្ហាញពីការរំលោភបំពានជាច្រើនក្នុងវិស័យសម្បទានដីសេដ្ឋកិច្ចដែលនៅតែបន្តឥតឈប់ឈរ ហើយដែលនីទណ្ឌភាពតែងមានប្រៀបជាង ។ មានការចោទប្រកាន់មួយចំនួនដែរ តែផ្ទុយទៅវិញ ជនរងគ្រោះដោយការរំលោភបំពាននោះត្រូវបានផ្តន្ទាទោសទៅវិញ ។

របាយការណ៍លំអិតមួយរបស់អង្គការGlobal Witnessបានបោះពុម្ពផ្សាយកាលពីថ្ងៃទី១ ខែមិថុនា ស្ដីពីសម្បទានព្រៃ និងការកាប់បំផ្លាញព្រៃឈើ ចោទប្រកាន់ពីការរំលោភច្បាប់ជាច្រើន ដោយអ្នកដែលជិតស្និទ្ធនឹងអាជ្ញាធរខ្ពស់បំផុតដែលពាក់ព័ន្ធនឹងដីធ្លី ។ របាយការណ៍នោះ បានផ្ដល់អនុសាសន៍សំខាន់ៗជាច្រើន ដល់រដ្ឋាភិបាលដើម្បីដោះស្រាយ និងកែតម្រូវបញ្ហាទាំងនោះ។ ប៉ុន្តែ ការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះរបាយការណ៍នោះ គឺជាការហាមប្រាមរបាយការណ៍ និងការស្ដីបន្ទោសដល់អង្គការ Global Witness ទៅវិញ។

*សិទ្ធិសហជីពកម្មករ*

អនាគតនៃចលនាសហជីពកម្មករឯករាជ្យមួយក្នុងប្រទេសកម្ពុជា កំពុងស្ថិតក្រោមការគំរាមកំហែង។ ខ្ញុំបានរៀបរាប់អំពីករណីឃាតកម្មលើ**លោកជា វិជ្ជា** ដែលមិនទាន់បានដោះស្រាយនៅឡើយ។ ខ្ញុំសោកស្ដាយណាស់ដែលត្រូវតែរាយការណ៍ថា ប្រធានសហជីពកម្មករម្នាក់ទៀត គឺ **លោកហ៊ី វុទ្ធី** ត្រូវបានគេសំលាប់ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៧ តាមរូបភាពស្រដៀងគ្នាបំផុតនឹងឃាតកម្មលើ **លោកជា វិជ្ជា**។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួនទេ រហូតមកទល់ពេលនេះ។ គេបានសំដែងការភ័យខ្លាច ប្រាប់ខ្ញុំថា នឹងមានជនស្លូតត្រង់ច្រើនទៀត អាចត្រូវចាប់ខ្លួន និងចោទប្រកាន់ពីបទឃាតកម្មនេះ។

ករណីឃាតកម្មនេះគឺជាសញ្ញាបង្ហាញពីបរិយាកាសគំរាមកំហែង ដែលក្នុងនោះសហជីពកម្មករត្រូវតែធ្វើការ។ និទណ្ឌភាពនៃការសំលាប់នេះនឹងបញ្ជាក់យ៉ាងច្បាស់ ពីការសមគំនិតរបស់រដ្ឋក្នុងការរក្សាឱ្យមានបរិយាកាសបែបនេះ។ នៅក្នុងរបាយការណ៍ ("កម្ពុជាៈ ការសំលាប់ ការរំលោភបំពាន ការបំភិតបំភ័យ និងការរើសអើង" ខែឧសភា ឆ្នាំ២០០៧) សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ផ្ដល់មតិលើការខកខានរបស់រដ្ឋាភិបាលមិនបានការពារសិទ្ធិបង្កើតសមាគម ដែលបង្ហាញឱ្យឃើញពីការខ្វះ "ឆន្ទៈនយោបាយ និងធ្វើអោយច្រឡំពីទំនាក់ទំនងនយោបាយជាមួយនិយោជក និងប្រធានសហជីពកម្មករ។ ការស្នើសុំធ្វើបាតុកម្ម ឬកូដកម្មដោយសន្តិវិធី ត្រូវបានបដិសេធជាប្រចាំ ហើយប្រសិនបើបាតុកម្មកើតឡើង បាតុកម្មទាំងនោះត្រូវបានបង្ក្រាបយ៉ាងឆាប់រហ័ស ដោយប្រើកំលាំងហួសហេតុ។ របាយការណ៍នេះបញ្ជាក់ថា " កម្មករ ប្រធានសហជីពកម្មករ សកម្មជន និងសមាជិកជាច្រើនបានរងរបួស ការបំភិតបំភ័យ និងការសម្លាប់ដោយការសងសឹកយ៉ាងកម្រោល និងការចាប់ខ្លួនដោយបង្ខំ។

នៅពេលដែលខ្ញុំបានលើកឡើងពីក្ដីកង្វល់របស់ខ្ញុំជាមួយរដ្ឋាភិបាលអំពីការរឹតត្បិត និងការគំរាមកំហែងដល់ចលនាសហជីពកម្មករ គេបានប្រាប់ខ្ញុំថា ការរឹតត្បិតជួនកាលមានភាពចាំបាច់ដើម្បីលើកទឹកចិត្តដល់វិនិយោទុនបរទេស និងដើម្បីធានាផលប្រយោជន៍ដល់វិនិយោគិនបរទេស។ ទោះជាមានសេចក្ដីថ្លែងការណ៍របស់អង្គការមួយ អង្គការធុរកិច្ចសំរាប់ការទទួលខុសត្រូវសង្គម ដែលជាសម្ព័ន្ធអង្គការមួយនៃបណ្ដុំក្រុមហ៊ុនជាច្រើន បានធ្វើការរិះគន់ការសំលាប់ **លោកហ៊ី វុទ្ធី** និងបានសំដែងនូវកង្វល់របស់ខ្លួនអំពីបញ្ហានេះ ជាពាក្យពេចន៍ថា " អ្វីដែលកើតឡើងជាលំនាំមួយនៃអំពើហឹង្សាប្រឆាំងនឹងប្រធានសហជីពកម្មករ"។

*ដីធ្លី និងការចិញ្ចឹមជីវិត*

នៅរាល់ដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំបានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើបញ្ហាដីធ្លី ។ កម្ពុជា គឺជាសង្គមកសិកម្មមួយយ៉ាងធំ ដែលពឹងផ្អែកលើដី និងធនធានធម្មជាតិ ។ ទន្ទឹមនឹងនេះ ដីបានក្លាយជាកត្តានៃការរិះគន់ និងវាទប្បដិវាទ នៅក្នុងការអភិវឌ្ឍន៍កសិកម្ម និងឧស្សាហកម្មទ្រង់ទ្រាយធំ ។ របៀបដែលកម្ពុជាគ្រប់គ្រង និងបែងចែកដីធ្លី និងធនធានធម្មជាតិរបស់ខ្លួន និងសំរាប់ផលប្រយោជន៍របស់អ្នកណា គឺជាបញ្ហាបន្ទាន់បង្គំបំផុត ដែលប្រទេសនេះប្រឈមមុខ ។ បុព្វធិការីរបស់ខ្ញុំបានធ្វើការស្វែងយល់អំពីវិសាលភាពដ៏សំខាន់មួយនៃគោលនយោបាយដីធ្លី  សម្បទានដីសេដ្ឋកិច្ច ។

ខ្ញុំទើបតែបានចេញផ្សាយ ពីការធ្វើបច្ចុប្បន្នភាព នៃរបាយការណ៍ ឆ្នាំ២០០៤ ដ៏មានតំលៃ របស់បុព្វធិការីរបស់ខ្ញុំ លើប្រធានបទនេះ ។ របាយការណ៍នេះ រកឃើញថា ជាលទ្ធផលនៃការខនខានមិនបានគោរពតាមក្របខ័ណ្ឌច្បាប់ស្តីពីសម្បទានដី សម្បទានដីសេដ្ឋកិច្ចបានទន្ទ្រានលើដី និងធនធានព្រៃឈើរបស់សហគមន៍នានា ដោយមានផលប៉ះពាល់ជាអវិជ្ជមានលើសិទ្ធិ និងជីវភាពរស់នៅរបស់ពួកគេ ។ ប្រព័ន្ធតុលាការ បានខកខានក្នុងការលើកស្ទួយសិទ្ធិរបស់សហគមន៍ដែលទទួលផលប៉ះពាល់  និងការគោរពច្បាប់ ។

ស្ថានការទូទៅពាក់ព័ន្ធនឹងដីធ្លីបានធ្លាក់ដុនដាបខ្លាំង ។ ប្រជាជនកាន់តែច្រើនឡើងត្រូវបានជម្លៀសចេញពីដីធ្លីរបស់ពួកគេ ទាំងនៅតំបន់ជនបទក៏ដូចជានៅទីក្រុង ដោយការប្រើប្រាស់កំលាំងហួសហេតុ ។ សិទ្ធិ និងការចិញ្ចឹមជីវិតជាមូលដ្ឋានរបស់ពួកគេ ត្រូវបានទទួលរងការឈឺចាប់ ។ របាយការណ៍ស្រាវជ្រាវមួយនៅពេលថ្មីៗនេះបានរកឃើញថា ការបាត់បង់ដីធ្លីដោយមិនស្ម័គ្រចិត្ត គឺជាហេតុផលដ៏ចម្បងមួយចំពោះភាពក្រីក្រ នៅតាមជនបទប្រទេសកម្ពុជា ។ ជាពិសេស ក្នុងគ្រួសារដែលមានស្ត្រីជាមេផ្ទះគឺមានសិទ្ធិលើធនធានដីធ្លីទាបជាង ទោះបីជាស្ត្រីដើរតួនាទីសំខាន់ក្នុងវិស័យកសិកម្មក៏ដោយ ។ មានការកើនឡើងបីដងក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៦ ពោលគឺផ្ទុយនឹងអនុសាសន៍របស់ខ្ញុំ និងអនុសាសន៍របស់បុព្វធិការីរបស់ខ្ញុំ ចំពោះការកើនឡើងនៃភាពគ្មានដីធ្លីសំរាប់ប្រជាជននៅតំបន់ជនបទ ។ នៅក្នុងបរិបទនេះ ខ្ញុំសូមស្នើយ៉ាងទទូចដល់រដ្ឋាភិបាល អោយបញ្ជូនរបាយការណ៍លើកទីមួយ និងហួសកំណត់យូរមកហើយរបស់ខ្លួន អំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។

*សិទ្ធិជនជាតិដើមភាគតិច*

ជនជាតិដើមភាគតិចនៅតែបន្តទទួលរងការឈឺចាប់ ដោយការបាត់បង់ដីប្រពៃណីរបស់ខ្លួន តាមរយៈការចាប់យកដី និងការផ្តល់សម្បទានផ្សេងៗ ។ ខ្ញុំបានទទួលការធានា នៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំ កាលពីឆ្នាំ ២០០៦ ថា អនុក្រឹត្យស្តីពីដីជនជាតិដើមភាគតិច នឹងត្រូវចេញក្នុងពេលដ៏ខ្លីខាងមុខនេះដែលនឹងការពារសិទ្ធិរបស់ពួកគេ ។ ប៉ុន្តែរហូតមកដល់ពេលនេះ នៅមិនទាន់មានអនុក្រឹត្យនេះនៅឡើយទេ តែខ្ញុំដឹងថាឯកសារគោលនយោបាយមួយ កំពុងត្រូវបានរៀបចំ – សេចក្តីព្រាងដំបូងមួយ មិនស្របនឹងការការពារសិទ្ធិជាសមូហភាព ដែលបានធានា ការពារក្នុងច្បាប់ភូមិបាល

ទេ។ ទន្ទឹមនឹងនេះ សហគមន៍ជនជាតិដើមភាគតិច បន្តបាត់បង់ដីធ្លីរបស់ខ្លួន ដែលបណ្តាលមកពីការគាបសង្កត់កាន់តែកើនឡើង ពីគំនិតផ្តួចផ្តើម "ការអភិវឌ្ឍន៍"។ រដ្ឋាភិបាលបានចង្អុលប្រាប់ពីចេតនារបស់ខ្លួន ដើម្បីដាក់ខេត្តមួយចំនួននៅភាគឦសាននៃកម្ពុជា ( រួមទាំងខេត្តដែលមានជនជាតិដើមភាគតិចច្រើន គឺខេត្តរតនគិរី និងមណ្ឌលគិរី ) ជា "ប៉ូលអភិវឌ្ឍន៍ទីបួន" របស់កម្ពុជានៅត្រឹមឆ្នាំ២០១៥។ ត្រូវតែចាត់វិធានការជាបន្ទាន់ ដើម្បីការពារសិទ្ធិជនជាតិដើមភាគតិចលើដីធ្លី។

រដ្ឋាភិបាលបានលំអៀងទៅរកការគាំទ្រក្រុមហ៊ុនពាណិជ្ជកម្ម នៅពេលដែលផលប្រយោជន៍របស់ពួកគេប៉ះទង្គិចនឹងផលប្រយោជន៍របស់ប្រជាជននៅជនបទ ឬទីក្រុង។ មានការគាំទ្រជាច្រើនចំពោះក្រុមហ៊ុន ហើយក្រុមហ៊ុនធំបំផុតមួយចំនួនគ្រប់គ្រងដោយអ្នកមានឥទ្ធិពលនយោបាយខ្លាំង ត្រូវបានផ្តល់អោយដោយការរំលោភច្បាប់។ ការរំលោភច្បាប់បានក្លាយជាកត្តាសំខាន់មួយក្នុងប្រតិបត្តិការ និងការរកផលកំរៃរបស់ក្រុមហ៊ុនមួយចំនួន ហើយបានធ្វើឱ្យខ្សោយជាបន្ថែមទៀតដល់នីតិរដ្ឋ។

*ការសន្និដ្ឋាន*

នៅក្នុងរបាយការណ៍ទីមួយរបស់ខ្ញុំ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស និងនៅក្នុងការកត់សំគាល់របស់ខ្ញុំជូនរដ្ឋាភិបាលកម្ពុជា និងសមាជិកសហគមន៍អន្តរជាតិ នៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំបញ្ជាក់ពីសារសំខាន់នៃការប្រើប្រាស់គោលដៅផ្អែកលើសិទ្ធិ ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ។ ឧទាហរណ៍មួយចំនួនខ្ញុំបានផ្តល់ដែលហៅថា "ការអភិវឌ្ឍន៍" នៅក្នុងវិស័យព្រៃឈើ និងច្បាប់ បង្ហាញថា កំនើនសេដ្ឋកិច្ចដោយខ្លួនឯងមិនអាចដោះស្រាយបញ្ហាបន្ទាន់បង្ខំ នៃភាពក្រីក្រ និងការដកហូតសិទ្ធិទេ។ ពិតណាស់ វាបានបន្ថែមទំងន់ទៅលើបញ្ហាទាំងនេះវិញទេ។ សេចក្តីថ្លៃថ្នូរជាមនុស្ស សមធម៌ ការបំពេញបានសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជន ការចូលរួម ព្រមទាំងការអភិវឌ្ឍន៍សមត្ថភាពរបស់ប្រជាជន និងការជ្រើសរើស គឺស្ថិតក្នុងចំណោមតំលៃ និងគោលដៅសំខាន់ៗដទៃទៀតនៃសិទ្ធិមនុស្ស។ ការអនុវត្តន៍ និងគោលនយោបាយសេដ្ឋកិច្ច និងនយោបាយនៅកម្ពុជា មិនបានស្របទៅនឹងសារសំខាន់ជាក់ស្តែងដល់តំលៃទាំងនេះទេ។

វណ្ណៈសង្គមអ្នកមានអំណាច និងមានទ្រព្យសម្បត្តិច្រើន បានអណ្តែតខ្លួនឡើងនៅពីក្រោយខ្នងរដ្ឋ - តាមរយៈការកេងប្រវ័ញ្ចពីប្រជាជន និងពីធនធានរបស់ប្រទេស ដោយផ្អែកលើការប្រើប្រាស់និងការប្រមូលយកបរិធានរបស់រដ្ឋ ។ ភាពខុសគ្នានៃទ្រព្យសម្បត្តិ និងការប្រើប្រាស់ចំណូល និងឱកាសក្នុងចំណោមប្រជាជនមានគំលាតធំក្នុងសភាពមួយគួរឱ្យព្រួយបារម្ភ។ ការជឿទុកចិត្តលើភាពមិនលំអៀងរបស់រដ្ឋបានចុះខ្សោយ។ ប្រទេសមួយដែលទើបងើបចេញពីជំលោះដ៏តានតឹងបែបនេះ និងការគាបសង្កត់ខ្លាំងដូចជាប្រទេសកម្ពុជា ត្រូវការកសាងទំនុកចិត្តក្នុងចំណោមសហគមន៍ និងរវាងសហគមន៍និងសហគមន៍ ព្រមទាំងរវាងសហគមន៍ និងរដ្ឋ។ ការកសាងទំនុកចិត្តអាចធ្វើបាន លុះត្រាតែឈរលើការគោរពសិទ្ធិស្មើគ្នានៃប្រជាជនគ្រប់រូប។

សហគមន៍អន្តរជាតិបានជំរុញជាយូរមកហើយ ដើម្បីបញ្ចប់និទណ្ឌភាព និងការបង្កើតនីតិរដ្ឋ ហើយបានដាក់ទុនជាហិរញ្ញវត្ថុ និងធនធានមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការជួយឱ្យសំរេចគោលបំណងនេះ ។ ប៉ុន្តែសហគមន៍អន្តរជាតិ មិនបានសំរេចជោគជ័យ ក្នុងការធ្វើឱ្យរដ្ឋាភិបាលចាប់អារម្មណ៍ពីសារសំខាន់នៃនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សតាមនីតិរដ្ឋទេ ។ ការខកខានមិនមាននីតិរដ្ឋ បានផ្តល់មូលដ្ឋានដ៏ល្អដល់អំពើពុករលួយ និងការធ្វើអាជីវកម្មលើផ្នែកទន់ខ្សោយរបស់សង្គម ។ ប្រហែលជាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅថ្ងៃខាងមុខ នឹងជួយបង្ហាញពីភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់ និងបង្កើនការគាបសង្កត់ឱ្យមានកំណែទម្រង់ ។ ប៉ុន្តែមានការព្រួយបារម្ភថា នៅពេលដែលធនធានប្រេង និងរ៉ែដទៃទៀតនៅកម្ពុជាដំណើរការនៅពេលដ៏ឆាប់ៗខាងមុខនេះ រដ្ឋាភិបាលនឹងមានការធ្វេសប្រហែសថែមទៀត អំពីនីត្យានុកូលភាព តម្លាភាព និងសិទ្ធិមនុស្សរបស់ប្រជាជន ។ ខ្ញុំសូមស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ ក្នុងការជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជា អនុវត្តវិធានការគ្រប់គ្រងប្រាក់ចំណូល ដូចមានចែងក្នុងគោលការណ៍ណែនាំរបស់អង្គការរូបិយវត្ថុអន្តរជាតិ (IMF) ស្តីពីតម្លាភាពនៃប្រាក់ចំណូលពីធនធាន និងដើម្បីចូលរួមក្នុងអង្គការគំនិតផ្តួចផ្តើមទាញយកប្រាក់ចំណូលពីឧស្សាហកម្មប្រកបដោយតម្លាភាព ។

ខ្ញុំបានផ្តល់នូវអ្វីដែលខ្ញុំយល់ថា ជាអនុសាសន៍សំខាន់ៗក្នុងរបាយការណ៍របស់ខ្ញុំ ។ ខ្ញុំសង្ឃឹមថាក្រុមប្រឹក្សាសិទ្ធិមនុស្សនឹងពិនិត្យអនុសាសន៍ទាំងនេះ ហើយថារបាយការណ៍ និងអនុសាសន៍ទាំងនេះនឹងក្លាយជាកម្មវត្ថុនៃការពិភាក្សាថ្នាក់ជាតិ នៅក្នុងប្រទេសកម្ពុជា ។ រយៈពេលដប់ប្រាំឆ្នាំ បន្ទាប់ពីការស្តារប្រទេសកម្ពុជាឡើងវិញ ការសន្យា និងគោលបំណងសំខាន់ៗនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលបានចរចាជាអន្តរជាតិ នៅមិនទាន់បានបំពេញនៅឡើយទេ ។ ខ្ញុំជឿជាក់ថា ក្រុមប្រឹក្សាសិទ្ធិមនុស្សនឹងយកអស់សមត្ថភាព ដើម្បីធានាឱ្យសំរេចបានគោលដៅ និងការសន្យាទាំងនេះ ។